# សិទ្ធិ និងទំនួលខុសត្រូវរបស់អ្នក

បែបបទនេះសរសេរនូវអ្វីដែលក្រសួងសង្គមកិច្ចនៃរដ្ឋអូរិហ្គិន (DHS) និងអាជ្ញាធរសុខភាពនៃរដ្ឋអូរិហ្គិន (OHA) យល់ព្រមធ្វើសម្រាប់អ្នក។ ទាំងនេះគឺជា "សិទ្ធិ" របស់អ្នក។ វាក៏សរសេរនូវអ្វីដែលអ្នកយល់ព្រមធ្វើ នៅពេលដែលអ្នកដាក់ពាក្យសុំ ឬទទួលបានជំនួយណាមួយដូចខាងក្រោម៖

- ជំនួយសាច់ប្រាក់
- ជំនួយចេញថ្លៃមើលកូន
- ជំនួយអំពើហិង្សាក្នុងគ្រួសារ
- ជំនួយផ្នែកពេទ្យ
- ជំនួយម្ហូបអាហារ

ទាំងនេះគឺជា "ទំនួលខុសត្រូវ" របស់អ្នក។

សូមអានវាដោយយកចិត្តទុកដាក់។ អ្នកអាចសុំឱ្យបុគ្គលិកក្រសួង DHS ពន្យល់ពីបែបបទនេះដល់អ្នកបាន។ សូមសួរសំណួរ ប្រសិនបើមានអ្វីដែលអ្នកមិនយល់។ អ្នកយល់ព្រមធ្វើតាមរឿងមួយចំនួននៅពេលដែលអ្នក (និងគ្រួសាររបស់អ្នក) ទទួលបានជំនួយពី DHS ឬ OHA។ អ្នកប្រហែលជាអាចបាត់បង់ជំនួយទាំងនោះ ឬត្រូវសងថ្លៃទៅអោយ DHS ឬ OHA វិញ ប្រសិនបើអ្នកទទួលបានជំនួយច្រើនជាងអ្វីដែលអ្នកគួរទទួលបាន។

## សិទ្ធិរបស់អ្នក (អ្វីដែលអ្នកអាចរំពឹងបានពី DHS និង OHA)៖

- DHS និង OHA នឹងធ្វើការជាមួយអ្នកដោយការគោរព ប្រកបទៅដោយភាពយុត្តិធម៌ និងការគួរសម។
- អ្នកមានសិទ្ធិសួរ និងដាក់ពាក្យសុំជំនួយពីកម្មវិធីរបស់ DHS ឬ OHA ណាមួយក៏បាន។ យើងក៏ប្រហែលជាអាចបញ្ជូនអ្នកទៅកាន់សេវាកម្មផ្សេងទៀត ដែលអ្នកត្រូវការផងដែរ។
- អ្នកអាចស្នើសុំរកវិក័យប័ត្រសម្រាប់បែបបទណាមួយដែលអ្នកផ្ញើទៅក្រសួង DHS ឬ OHA បាន។
- អ្នកអាចសុំជួបនិយាយជាមួយបុគ្គលិកយើងបាន។ អ្នកក៏អាចសុំនិយាយជាមួយមេទទួលបន្ទុកការងារនោះបានដែរ។

- អ្នកអាចស្នើសុំកមនុស្សមកជួយអ្នកក្នុងការដាក់ពាក្យ បំពេញបែបបទ ឬរាយការណ៍នូវការផ្លាស់ប្តូរទៅតាមភាសាដែលអ្នកនិយាយបាន។
- DHS ឬ OHA នឹងផ្តល់ឱ្យអ្នកនូវព័ត៌មានជាទម្រង់ ឬភាសាណាដែលអ្នកអាចយល់បាន។
- DHS ឬ OHA នឹងប្រឹងប្រែងអស់ពីសមត្ថភាពដើម្បីបំពេញតាមតម្រូវការពិសេសរបស់អ្នក ប្រសិនបើអ្នកមានពិការភាព។ DHS និង OHA អនុវត្តតាមច្បាប់ជនពិការសហរដ្ឋអាមេរិក និងច្បាប់លេខ 504 នៃច្បាប់ស្តារនីតិសម្បទា។
- អ្នកអាចសុំមើលសេចក្តីថ្លែងការណ៍អំពីរូបអ្នក នៅក្នុងសំណុំរឿងរបស់អ្នកបាន។
- ប្រសិនបើអ្នកមាន "មូលហេតុសមរម្យ" អ្នកអាចសុំមិនសហការណ៍ជាមួយនឹងក្រសួងមើលការខុសត្រូវលើការចេញថ្លៃចិញ្ចឹមកូន។ មូលហេតុសមរម្យមានន័យថាការទារប្រាក់ឧបត្ថម្ភកូននឹងបង្កគ្រោះថ្នាក់ដល់អ្នក ឬកូនរបស់អ្នក។ DHS និង OHA នឹងផ្តល់ឱ្យអ្នកនូវបែបបទដែលពន្យល់ពីមូលហេតុសមរម្យ។ បែបបទទាំងនេះប្រាប់អ្នកពីរបៀបដែលកម្មវិធីមើលការខុសត្រូវលើការចេញថ្លៃចិញ្ចឹមកូននៃរដ្ឋអូរិហ្គិន ប្រហែលជាអាចជួយអ្នកទទួលបានការចេញថ្លៃចិញ្ចឹមកូន រួមទាំងជំនួយសាច់ប្រាក់សំរាប់បង់ធានារ៉ាប់រងពេទ្យ ខណៈពេលដែលរក្សាអ្នក និងកូនរបស់អ្នកឱ្យមានសុវត្ថិភាព។ DHS និង OHA ក៏អាចឆ្លើយនូវសំណួររបស់អ្នកអំពីមូលហេតុសមរម្យផងដែរ។
- អ្វីដែលអ្នកប្រាប់ទៅ DHS និង OHA យើងនឹងរក្សាជាការសម្ងាត់។ អ្នកអាចអានមើល 'សេចក្តីជូនដំណឹងអំពីការអនុវត្តនូវការរក្សាការសម្ងាត់' របស់យើងនៅតាមអីនធឺណែតនៅ https://apps.state.or.us/Forms/Served/me2090.pdf ឬមានដាក់បិទផ្សាយនៅក្នុងក្រសួង DHS ។
- ប្រសិនបើអ្នកជាមនុស្សចាស់ អ្នកមានសិទ្ធិទទួលបានស្ទែកពីកម្មវិធីផ្តល់អាហាររូបត្ថម្ភដោយផ្ទាល់ពីកសិដ្ឋានសំរាប់មនុស្សចាស់ (SFDNP) ប្រសិនបើអ្នកមានសិទ្ធិ។ ទោះយ៉ាងណាក៏ដោយ អ្នកមិនអាចទទួលបានជំនួយពីកម្មវិធីអាហាររូបត្ថម្ភដោយផ្ទាល់ពីកសិករសំរាប់មនុស្សចាស់ (SFMNP) ទេ បើអ្នកទទួលបានជំនួយនេះពីរដ្ឋមួយផ្សេងទៀត។
- DHS និង OHA នឹងប្រាប់អ្នកថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយនៅក្នុងរយៈពេល ដូចខាងក្រោម៖
    - 30 ថ្ងៃសម្រាប់ជំនួយអាហារ និងជំនួយសាច់ប្រាក់

- 30 ថ្ងៃសម្រាប់ជំនួយបណ្ដោះអាសន្នសម្រាប់ជនរងគ្រោះដោយអំពើហឹង្សាក្នុងគ្រួសារ (TA-DVS) - ការសម្រេចចិត្តបានធ្វើឡើងក្នុងរយៈពេល 16 ម៉ោងធ្វើការ បន្ទាប់ពីបំពេញបែបបទរបស់អ្នកជាមួយយើង លើកលែងតែអ្នកមិនសុំជំនួយទេ
- 45 ថ្ងៃសម្រាប់ជំនួយផ្សេងទៀត។
- 7 ថ្ងៃសំរាប់ជំនួយម្ហូបអាហារដែលសុំពន្លឿន ប្រសិនបើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់
- 90 ថ្ងៃសម្រាប់ការសម្រេចចិត្តផ្ដល់ជំនួយផ្នែកពេទ្យដោយផ្អែកលើពិការភាព (លើកលែងតែក្នុងកាលៈទេសៈពិសេសណាមួយ)

• អ្នកអាចស្នើសុំតវ៉ាបាន ប្រសិនបើអ្នកមិនយល់ស្របនឹងការសម្រេចចិត្តរបស់ DHS ឬ OHA។ អ្នកត្រូវតែបំពេញបែបបទស្នើសុំតវ៉ាផ្នែករដ្ឋបាល ( MSC 0443 ) នៅពេលដែលសំណើសុំតវ៉ាគឺទាក់ទងទៅនឹងអ្វីណាមួយដូចខាងក្រោម៖

- ជំនួយសាច់ប្រាក់
- ជំនួយ TA-DVS
- ជំនួយចេញថ្លៃមើលកូន

សមាជិកក្រសួង DHS អាចជួយអ្នកបំពេញសំណើសុំតវ៉ាបាន។ សម្រាប់ជំនួយម្ហូបអាហារ អ្នកអាចស្នើសុំតវ៉ាបានតាមទូរស័ព្ទ ជាលាយលក្ខណ៍អក្សរ ឬតវ៉ាដោយផ្ទាល់។ ប្រសិនបើអ្នកទទួលបានជំនួយមើលថែតាមផ្ទះ និងតាមសហគមន៍ ឬការមើលថែទាំតាមផ្ទះ នោះអ្នកគ្មានសិទ្ធិសម្រាប់សុំមិនសងសំណងពីអចលនទ្រព្យនោះទេ។ សូមស្វែងយល់បន្ថែមនៅក្នុងផ្នែកកម្មវិធីសំណងអចលនទ្រព្យ។ អ្នកត្រូវតែស្នើសុំតវ៉ាក្នុងរយៈពេល ដូចខាងក្រោម ប្រសិនបើអ្នកទទួលបានជំនួយទាំងនេះ៖

- 45 ថ្ងៃសម្រាប់ជំនួយសាច់ប្រាក់ ជំនួយជួយជនរងគ្រោះដោយអំពើហិង្សាក្នុងគ្រួសារ ឬជំនួយចេញថ្លៃមើលកូន
- 90 ថ្ងៃសម្រាប់ជំនួយសាច់ប្រាក់ ប្រសិនបើអ្នកត្រូវបានគេដកសិទ្ធិដោយមិនធ្វើតាមគម្រោងនៃសំណុំរឿង JOBS របស់អ្នក។ នេះរាប់បញ្ចូលទាំងការដកសិទ្ធិដោយសារមិនទៅព្យាបាល ខាងក្រោម៖
  - សុខភាពផ្លូវចិត្ត
  - ការប្រើគ្រឿងញៀន
  - ការប្រើគ្រឿងស្រវឹង
- 90 ថ្ងៃសម្រាប់ជំនួយផ្នែកពេទ្យ និងជំនួយម្ហូបអាហារ

## ទំនួលខុសត្រូវរបស់អ្នក (អ្វីដែលអ្នកត្រូវធ្វើ)៖

### ប្រសិនបើអ្នកទទួលជំនួយពីកម្មវិធីរបស់ DHS ឬ OHA អ្នកត្រូវតែ៖

- ប្រាប់ទៅ DHS និង OHA នូវព័ត៌មានពិត ត្រឹមត្រូវ និងពេញលេញ។
- ផ្តល់នូវភស្តុតាងនៃរឿងមួយចំនួនដែលអ្នករាយការណ៍។ ប្រសិនបើអ្នកមិនអាចរកភ័ស្តុតាងនោះបានទេ អ្នកត្រូវតែអនុញ្ញាតឱ្យយើងទាក់ទងទៅអ្នកផ្សេង ឬក្រសួងផ្សេងទៀត សម្រាប់ភស្តុតាងនៅពេលដែលយើងត្រូវការ។
- ផ្តល់របាយការណ៍នៃការចំណាយសំរាប់ជំនួយ TA-DVS ។
- ចូលរួមក្នុងកម្មវិធីជួយរកការងារ និងវគ្គបណ្តុះបណ្តាល ប្រសិនបើយើងតម្រូវឱ្យអ្នកធ្វើដូច្នេះ។ យើងក៏ប្រហែលជាអាចតម្រូវឱ្យអ្នកស្វែងរក ទទួលយក និងរក្សានូវការងារដែលអ្នកមាន។ តម្រូវការនេះមិនអនុវត្តចំពោះកម្មវិធីជំនួយផ្នែកពេទ្យទេ។
- អនុញ្ញាតឱ្យបុគ្គលិក DHS និង OHA ទៅមើលផ្ទះរបស់អ្នក ដើម្បីទទួលបានព័ត៍មានសំរាប់សំណុំរឿងរបស់អ្នក។
- រាយការណ៍នូវការផ្លាស់ប្តូរទៅក្រសួង DHS និង OHA ។
- ជួយដល់ DHS និង OHA ទទួលបាននូវភស្តុតាង ប្រសិនបើសំណុំរឿងរបស់អ្នកត្រូវបានគេជ្រើសរើសសម្រាប់ការពិនិត្យឡើងវិញ។ សំណុំរឿងមួយចំនួនត្រូវបានគេចុចរើសដោយចៃដន្យ ដើម្បីយកទៅពិនិត្យមើលឡើងវិញ។
- អនុញ្ញាតឱ្យចេញផ្សាយនូវកំណត់ត្រាជំនួយចេញថ្លៃចិញ្ចឹមកូនរបស់អ្នកពីក្រសួងយុត្តិធម៌ នាយកដ្ឋានមើលការខុសត្រូវលើការចេញថ្លៃចិញ្ចឹមកូន ទៅអោយ DHS និង OHA លើកលែងតែអ្នកមានហេតុផលសមរម្យ។

### ប្រសិនបើអ្នកទទួលបានជំនួយម្ហូបអាហារ អ្នកក៏ត្រូវតែ៖

- ធ្វើនូវរឿងទាំងអស់ខាងក្រោមនេះ លើកលែងតែអ្នកមានហេតុផលសមរម្យ៖
  - មិនសុំលាឈប់ពីការងារទេ
  - មិនបន្ថយម៉ោងធ្វើការរបស់អ្នកឱ្យតិចជាង 30 ម៉ោងក្នុងមួយសប្តាហ៍ទេ
  - ទទួលយកការផ្តល់ជូនការងារណាមួយដែលមាន
- រាយការណ៍ និងផ្តល់នូវភស្តុតាងនៃការចំណាយខាងក្រោម ប្រសិនបើអ្នកចង់ឱ្យទូរលេខនោះគេយកទៅប្រើដើម្បីសុំជំនួយម្ហូបអាហាររបស់អ្នក៖

- ជំនួយផ្នែកពេទ្យ
- ជំនួយចេញថ្លៃទឹកភ្លើងកំដៅហ្គាស
- ដីកាចេញថ្លៃចិញ្ចឹមកូន
- មើលថែមនុស្សក្នុងបន្ទុក

ប្រសិនបើអ្នកមិនរាយការណ៍អំពីការចំណាយទាំងនេះ ឬផ្ទៀងផ្ទាត់វានៅពេលយើងសួរទេ អញ្ចឹងទូរលេខនោះនឹងមិនត្រូវបានគេយកទៅប្រើប្រាស់ដើម្បីស្វែងរកជំនួយម្ហូបអាហាររបស់អ្នកទេ។ ប្រសិនបើអ្នកមិនរាយការណ៍អំពីការផ្លាស់ប្តូរ និងទទួលបានជំនួយច្រើនពេក នោះអ្នកប្រហែលជាត្រូវសងថ្លៃចេញលើសទៅអោយ DHS ឬ OHA វិញ។

- ចូលរួមក្នុងផែនការការងារ និងវគ្គបណ្តុះបណ្តាលណាមួយដែលផ្តល់ជូនអ្នកដោយ DHS ឬ OHA ឬភ្នាក់ងារដៃគូរបស់យើង។

**ប្រសិនបើអ្នកទទួលបានជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារដែលខ្វះខាត (TANF) ឬជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន អ្នកក៏ត្រូវតែ៖**

- ធ្វើការពិនិត្យសុខភាពតាមដែលអ្នកត្រូវការ ដើម្បីមើលថាតើអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់សេវាកម្មជាក់លាក់ណាដែរឬទេ។
- ស្នើសុំ និងប្រើប្រាស់ជំនួយ ឬប្រាក់ផ្សេងទៀតដែលអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួលជំនួយ។ អ្នកត្រូវតែធ្វើបែបនេះសម្រាប់អ្នក និងអ្នកដទៃដែលគាត់ចង់បានជំនួយដែរ។ នេះប្រហែលជាអាចរួមបញ្ចូលដូចខាងក្រោម៖
    - ជំនួយធានារ៉ាប់រងពេលអត់ការងារធ្វើ
    - ជំនួយសួស្បាល់សេគ្គរិទី
    - ជំនួយធានារ៉ាប់រងរបួសស្នាមផ្ទាល់ខ្លួនដោយអ្នកគ្មានកំហុស ដែលមាននៅក្នុងការធានារ៉ាប់រងយានយន្តទាំងអស់
- ទទួលយកសេវាសង្គមដែលជាដីកាពីតុលាការ ឬពាក់ព័ន្ធនឹងការបណ្តុះបណ្តាល ឬរកការងារធ្វើ។
- សូមចូលទៅកាន់កម្មវិធីសុខភាពផ្លូវចិត្ត និងការផ្តាច់គ្រឿងញៀន ឬគ្រឿងស្រវឹង ប្រសិនបើ DHS ឬ OHA កំណត់ថាអ្នកត្រូវការជំនួយនោះ។ អ្នកត្រូវតែធ្វើដូចនេះ ប្រសិនបើអ្នកអាចចូលចូលរួមក្នុងកម្មវិធីដែលឥតគិតថ្លៃសម្រាប់អ្នក។
- រាយការណ៍ទៅក្រុមហ៊ុនធានារ៉ាប់រងរបួសស្នាមផ្ទាល់ខ្លួនក្នុងរយៈពេល 10 ថ្ងៃ ប្រសិនបើ **អ្នក ឬនរណាម្នាក់ក្នុងគ្រួសាររបស់អ្នក** ទទួលបានជំនួយទាំងពីរខាងក្រោម៖
    - ទទួលបានជំនួយ TANF ។

- ○ មានការប្ដឹងទាមទារសំណងពីនរណាម្នាក់ដែលធ្វើអោយអ្នករងរបួស។

**នៅក្នុងជំនួយ TANF អ្នកត្រូវតែជួយក្នុងការចិញ្ចឹមកូន លុះត្រាតែ៖**

- មានករណីណាមួយខាងក្រោម៖
    - ○ អ្នកស្ថិតនៅក្នុងកម្មវិធី JOBS Plus
    - ○ អ្នកទើបចាប់ផ្ដើមចូលនៅក្នុងកម្មវិធីធានារ៉ាប់រងសូស្យាល់សេគ្យូរិទីគ្រួសារក្នុងរដ្ឋ (SSI) និងកម្មវិធីធានារ៉ាប់រងពិការភាពពីសូស្យាល់សេគ្យូរិទី (SSDI) (SFPSS)
    - ○ អ្នកស្ថិតនៅក្នុងកម្មវិធី Post-TANF
    - ○ អ្នកមានសិទ្ធិទទួលបានជំនួយសាច់ប្រាក់សម្រាប់គ្រួសារដែលជាគ្រួសារដែលមានឪពុកម្ដាយពីរនាក់
    - ○ អ្នកកំពុងទទួលបានប្រាក់ឈ្នួលពីការងារ
- វានឹងបង្កគ្រោះថ្នាក់ដល់អ្នក និងកូនរបស់អ្នក។ ត្រូវប្រាកដថាប្រាប់ទៅ DHS ឬ OHA ។

**ប្រសិនបើអ្នកទទួលបានជំនួយចេញថ្លៃមើលកូនពេលទៅធ្វើការងារ (ERDC) អ្នកត្រូវតែ៖**

- បង់ថ្លៃចំណែកត្រូវបង់ជំនួយ ERDC របស់អ្នកទៅឱ្យអ្នកមើលកូនរបស់អ្នកជារៀងរាល់ខែ ដើម្បីបន្តសិទ្ធិទទួលជំនួយ។
- សូមប្រាប់ទៅ DHS ភ្លាមៗ ប្រសិនបើអ្នកអស់ការងារធ្វើ ឬអ្នកកំពុងឈប់សម្រាកដោយសារបញ្ហាផ្នែកពេទ្យ។ DHS ប្រហែលជាអាចបន្តបង់ប្រាក់ចេញថ្លៃមើលកូន ខណៈពេលដែលអ្នកស្វែងរកការងារធ្វើ ឬអំឡុងពេលដែលអ្នកឈប់សម្រាកពីការងារដោយសារបញ្ហាផ្នែកពេទ្យរបស់អ្នក។
- អ្នកមានសិទ្ធិជ្រើសរើសអ្នកមើលកូនអោយអ្នក។ សូមទាក់ទងទៅ DHS ឬទូរស័ព្ទទៅលេខ 211 ដើម្បីទទួលបានជំនួយក្នុងការស្វែងរកអ្នកមើលកូន។
- សូមជ្រើសរើសអ្នកមើលកូនណាដែលអាចធ្វើតាមអ្វីៗទាំងអស់ ដែលតម្រូវពី DHS ដែលមានដូចខាងក្រោម៖
    - ○ បំពេញតាមតម្រូវការជាអ្នកមើលកូន
    - ○ បំពេញតាមស្តង់ដារសុខភាព និងសុវត្ថិភាព
    - ○ ត្រូវចុះក្នុងបញ្ជី និងបានយល់ព្រមពីក្រសួង

**ប្រសិនបើអ្នកទទួលបានជំនួយផ្នែកពេទ្យ អ្នកត្រូវតែ៖**

- ស្នើសុំ និងប្រើប្រាស់ជំនួយជាក់លាក់ ឬប្រាក់ដែលអ្នកមានលក្ខណៈសម្បត្តិគ្រប់គ្រាន់ក្នុងការទទួល។ នេះប្រហែលជាអាចរួមបញ្ចូលនូវអ្វីណាមួយខាងក្រោម៖
    - លុយសូស្យាល់សេគួរិទី
    - លុយចូលនិវត្តន៍សំរាប់បុគ្គលិកផ្លូវដែក
    - ជំនួយសំរាប់អតីតយុទ្ធជន
    - ជំនួយបង់ថ្លៃផ្ទះ និងបង់សហជីព
    - ជំនួយធានារ៉ាប់រងរបួសស្នាមផ្ទាល់ខ្លួនដោយអ្នកគ្មានកំហុស ដែលមាននៅក្នុងការធានារ៉ាប់រងយានយន្តទាំងអស់
    - លុយធានារ៉ាប់រងសំណងសំរាប់បុគ្គលិក
    - ជំនួយធានារ៉ាប់រងថែទាំរយៈពេលវែង
    - ជំនួយធានារ៉ាប់រងផ្នែកពេទ្យ
    - ជំនួយមេឌីឃែរ
- សូមធ្វើតេស្តសុខភាពណាមួយដែលអ្នកត្រូវការ ដើម្បីបំពេញពាក្យសុំជំនួយផ្នែកពេទ្យ។
- ប្រាប់ទៅពេទ្យរបស់អ្នក ប្រសិនបើអ្នកមានការធានារ៉ាប់រងសុខភាពផ្សេងទៀត។ ឧទាហរណ៍មានសរសេរដូចខាងក្រោម៖
    - ជំនួយមេឌីឃែរ
    - ជំនួយសំរាប់អតីតយុទ្ធជន
    - ការធានារ៉ាប់រងលើសំណងបុគ្គលិក
    - ការធានារ៉ាប់រងរបួសផ្ទាល់ខ្លួនដោយអ្នកគ្មានកំហុស ដែលមាននៅក្នុងការធានារ៉ាប់រងយានយន្តទាំងអស់
    - ការធានារ៉ាប់រងសុខភាពផ្សេងទៀត។

  ពេទ្យទាំងអស់គួរតែចេញវិក្កយបត្រទៅក្រុមហ៊ុនធានារ៉ាប់រងជាមុនសិន មុនពេលពួកគេចេញវិក្កយបត្រទៅ DHS ឬ OHA សម្រាប់ការថែទាំសុខភាពរបស់អ្នក។

  ផ្តល់លេខអត្តសញ្ញាណប័ណ្ណពេទ្យដែលចេញដោយរដ្ឋរបស់អ្នកមុនពេលអ្នកទទួលសេវាកម្ម។

- ប្រសិនបើតម្រូវ សូមធ្វើការបង់ចំណែកត្រូវបង់ប្រចាំខែ ដើម្បីបន្តទទួលបានជំនួយផ្នែកពេទ្យ និងសេវាកម្មផ្សេងៗទៀត។ ចំនួនទឹកប្រាក់ទាំងនេះអាចកែតម្រូវ ផ្លាស់ប្តូរទៅតាមស្ថានភាពហិរញ្ញវត្ថុរបស់អ្នក។
- រាយការណ៍ទៅក្រុមហ៊ុនធានារ៉ាប់រងរបួសស្នាមផ្ទាល់ខ្លួនក្នុងរយៈពេល 10 ថ្ងៃ ប្រសិនបើ **អ្នក**

**ប្អូនណាម្នាក់ក្នុងគ្រួសាររបស់អ្នក** ទទួលបានជំនួយទាំងពីរខាងក្រោម៖

- ○ ទទួលបានជំនួយផ្នែកពេទ្យ ឬជំនួយពីគម្រោងសុខភាពនៃរដ្ឋអូរិហ្គិន (OHP)។
- ○ មានការប្តឹងទាមទារសំណងពីនរណាម្នាក់ដែលធ្វើអោយអ្នករងរបួស។

## ការទទួលស្គាល់ពីកម្មវិធី

### ព័ត៌មានអំពីជំនួយសាច់ប្រាក់

ជំនួយសាច់ប្រាក់ត្រូវបានគេស្គាល់ និងហៅឈ្មោះពីរខាងក្រោមនេះ៖

- ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារដែលខ្វះខាត (TANF)
- ជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន

ជំនួយជាសាច់ប្រាក់មានបំណងបំពេញតម្រូវការជាមូលដ្ឋានរបស់គ្រួសារនិមួយៗ។ ឧទាហរណ៍មានដូចខាងក្រោម៖

- ម្ហូបអាហារ
- សំលៀកបំពាក់
- ទីជម្រក
- ថ្លៃប្រើប្រាស់ផ្សេងៗ

ការចេញកាតលុយអេឡិចត្រូនិក (EBT) គឺជាវិធីមួយដែលមនុស្សភាគច្រើនទទួលបានជំនួយសាច់ប្រាក់នៅក្នុងរដ្ឋអូរិហ្គិន។ កាតនេះត្រូវបានគេស្គាល់ថាជាកាត Oregon Trail Card ។

កាតជំនួយសាច់ប្រាក់នេះមិនអាចយកទៅប្រើសម្រាប់ទៅទិញឬប្រើក្នុងហាងណាមួយដូចខាងក្រោមបានទេ៖

- ហាងលក់ស្រា នេះរួមបញ្ចូលទាំងហាងលក់រាយដែលលក់តែសុរា ឬភាគច្រើនលក់ស្រាបៀរ ឬស្រា។
- កាស៊ីណូ ឬកន្លែងលេងហ្គេម
- ហាងលក់របស់របរកម្សាន្តសម្រាប់មនុស្សពេញវ័យ ដែលមានរាំ ឬដាក់លក់របស់អាសអាភាស ។ នេះរួមបញ្ចូលទាំងហាងលក់វីដេអូអាសអាភាស ដែលភាគច្រើនលក់ ឬដាក់តាំងនូវវីដេអូ ឬភាពយន្តអាសអាភាស។
- កន្លែងលក់កញ្ឆា

ការរឹតបន្តឹងទាំងនេះអនុវត្តនៅគ្រប់ទីកន្លែងដែលអ្នកកំពុងប្រើកាត Oregon Trail Card ដើម្បីដក ឬចាយលុយជំនួយរបស់អ្នក។ ការរឹតបន្តឹងទាំងនេះក៏អនុវត្តផងដែរ នៅពេលដែលអ្នកដក ឬចាយលុយជំនួយពីគណនីធនាគារឯកជន។

ប្រសិនបើអ្នកទទួលបានជំនួយបណ្តោះអាសន្នសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ (TA-DVS)៖

ជំនួយបណ្តោះអាសន្នសម្រាប់ជនរងគ្រោះដោយសារអំពើហិង្សាក្នុងគ្រួសារ (TA-DVS) គឺជាជំនួយសាច់ប្រាក់ដើម្បីផ្តល់៖

- ជំនួយហិរញ្ញវត្ថុបណ្តោះអាសន្ន និងជំនួយដល់គ្រួសារដែលរងផលប៉ះពាល់ដោយអំពើហិង្សាក្នុងគ្រួសារ។
  - ក្នុងពេលមានវិបត្តិ ឬស្ថានភាពបន្ទាន់។
  - នៅពេលដែលធនធានផ្សេងទៀតមិនមានសំរាប់ពួកគាត់។

ជំនួយ TA-DVS ត្រូវបានបង់ជាស្នែកទៅអ្នកផ្តល់សេវាកម្ម ឬអ្នកដែលត្រូវទទួលប្រាក់។

DHS នឹងសួរសំណួរអំពីស្ថានភាពហិង្សាក្នុងគ្រួសាររបស់អ្នក។ មុនពេលដែលយើងយល់ព្រមចេញថ្លៃជំនួយ នោះDHS តម្រូវឱ្យអ្នកបង្កើតនូវផែនការសុវត្ថិភាពជាមួយយើងជាមុនសិន។ ការផ្ទៀងផ្ទាត់គឺជាការចាំបាច់សម្រាប់រាល់ការចេញថ្លៃជំនួយ TA-DVS ។ មូលនិធិដែលមិនត្រូវបានគេយកទៅប្រើប្រាស់សម្រាប់សុវត្ថិភាពក្នុងអំឡុងពេលអ្នកមានសិទ្ធិទទួលបាន 90 ថ្ងៃ អញ្ចឹងលុយនោះនៅរក្សាជាមួយ DHS ។ ប្រសិនបើអ្នកស្នើសុំជំនួយសំរាប់អំពើហឹង្សាក្នុងគ្រួសារច្រើនជាងម្តងក្នុងរយៈពេល 12 ខែ ពាក្យសុំជំនួយជាថ្មីរបស់អ្នកអាចទាមទារនូវការពិនិត្យមើលឡើងវិញ។

ប្រសិនបើអ្នកទទួលបានជំនួយ TANF៖

ការចាត់តាំងនូវការចេញថ្លៃ និងថ្លៃជំពាក់

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ជំនួយ TANF អ្នកត្រូវតែអនុញ្ញាតឱ្យ DHS ឬ OHA ទទួលបានប្រាក់ដែល៖

- អ្នក ឬអ្នកផ្សេងទៀតដែលទទួលបានជំនួយ TANF ជាមួយអ្នក ទទួលបាន ឬមានសិទ្ធិទទួលបានសំណងនៃការរងរបួសស្នាមតាមផ្លូវច្បាប់ ។

នេះរួមបញ្ចូលទាំងប្រាក់ដែលបានមកពីអ្វីមួយដូចខាងក្រោម៖

- ក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជន
- ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត
- ជនណាម្នាក់
- ប្រភពផ្សេងទៀត។

ខាងលើនេះត្រូវបានគេហៅថា "ការចាត់តាំងនូវការចេញថ្លៃ" ទៅអោយ DHS ឬ OHA ។ ដើម្បីបន្តទទួលបានជំនួយ TANF អ្នកនិងសមាជិកគ្រួសារផ្សេងទៀត (ដែលរាប់បញ្ចូលទាំងកូនដែលនឹងត្រូវកើត) ត្រូវតែជួយ DHS ឬ OHA ក្នុងការស្វែងរក និងទទួលបាននូវការចេញថ្លៃទាំងនេះតាមវិធីខាងក្រោមទាំងអស់៖

- ប្រាប់ DHS, OHA និងអង្គការផ្តល់កិច្ចគាំពារដែលមានការសម្របសម្រួល (CCO) របស់អ្នក ថាភាគីទីបីធ្វើឱ្យអ្នក ឬសមាជិកក្នុងគ្រួសាររងរបួស ក្នុងរយៈពេល 10 ថ្ងៃ។
- ផ្តល់ព័ត៌មានអំពីភាគីដែលបណ្តាលឱ្យអ្នករងរបួស។
- ជួយផ្តល់នូវព័ត៌មានផ្សេងទៀតដែលបានស្នើសុំ។ នេះរួមបញ្ចូលទាំងព័ត៌មានធានារ៉ាប់រង។ មានដែនកំណត់លើប្រាក់ដែល

DHS ឬ OHA ដែលអាចទទួលយកបាន។

វាមិនអាចលើសពីចំនួនដែលបានបង់គិតចាប់ពីថ្ងៃនៃការរងរបួសដល់ពេលដែលអ្នកត្រូវបានគេបង់ថ្លៃអោយពីភាគីដែលទទួលខុសត្រូវចំពោះសំណងនៃការរងរបួសនោះទេ។ ប្រសិនបើមានករណីទាំងពីរខាងក្រោមកើតឡើង អ្នកក៏ប្រហែលជាត្រូវសងយើងវិញផងដែរនូវ៖

- ជំនួយផ្នែកពេទ្យពី DHS ឬ OHA បានបង់ថ្លៃសេវាពេទ្យ។
- អ្នកទទួលបានការចេញថ្លៃពីអ្នកដែលទទួលខុសត្រូវចំពោះការរងរបួសស្នាមរបស់អ្នក។

សូមមើលផ្នែកព័ត៌មានអំពីជំនួយសាច់ប្រាក់។

អ្វីដែលអ្នកត្រូវដឹងអំពី "ការចាត់តាំងនូវការចេញថ្លៃចិញ្ចឹម"

"ការចេញថ្លៃចិញ្ចឹម" មានន័យថាជាប្រាក់ដែលអ្នកទទួលបានសម្រាប់អ្នក ឬកូនរបស់អ្នក ដូចជាប្រាក់ឧបត្ថម្ភប្តីប្រពន្ធក្រោយពេលលះលែងគ្នា ឬប្រាក់ឧបត្ថម្ភកូនជាដើម។ នៅពេលដែលអ្នកទទួលបានជំនួយសាច់ប្រាក់ អ្នក "ប្រគល់" សិទ្ធិឱ្យទៅរដ្ឋដើម្បីរក្សាទុកនូវលុយថ្លៃចិញ្ចឹមអ្នក ឬនរណាម្នាក់ក្នុងគ្រួសាររបស់អ្នកដែលទទួលបានពីមនុស្សម្នាក់ផ្សេងទៀត។ លុយនោះយកទៅសងរដ្ឋជាសាច់ប្រាក់ដែលអ្នកទទួលជំនួយ។ **ចំណាំ៖**

នេះមិនត្រូវបានគេអនុវត្តក្នុងអំឡុងពេលណាមួយដែលអ្នកទទួលបានជំនួយសាច់ប្រាក់ពីកម្មវិធីណាមួយដូចខាងក្រោមទេ៖

- JOBS Plus
- កម្មវិធី Pre-SSI/SSDI (SFPSS)
- កម្មវិធី Post-TANF
- នៅពេលដែលអ្នកជាគ្រួសារដែលមានឪពុកម្តាយពីរនាក់

- នៅពេលដែលអ្នកកំពុងទទួលបានការចេញថ្លៃពីការងារ។

ការចេញថ្លៃចិញ្ចឹមនៅពេលដែលអ្នកទទួលបានជំនួយសាច់ប្រាក់៖

រដ្ឋនឹងរក្សាទុកលុយថ្លៃចិញ្ចឹមមួយចំនួន (រាប់ទាំងថ្លៃជួយចិញ្ចឹមនាពេលបច្ចុប្បន្ន និងកន្លងមក) របស់អ្នក និងសមាជិកនៃគ្រួសាររបស់អ្នក។ រដ្ឋនឹងមិនរក្សាទុកលុយថ្លៃចិញ្ចឹមកូនរបស់អ្នកទាំងអស់ទេ។ រដ្ឋនឹងផ្ញើជូនអ្នកនូវថ្លៃចិញ្ចឹមចំនួន $50 សម្រាប់កូនម្នាក់ក្នុងមួយខែរហូតដល់ $200 សំរាប់មួយគ្រួសារក្នុងមួយខែ។ រដ្ឋនឹងមិនរាប់បញ្ចូលប្រាក់នេះជាចំណូលនៅពេលគណនាសិទ្ធិ និងជំនួយរបស់អ្នកទេ។

**ចំណាំ៖** ប្រសិនបើអ្នកដាក់ពាក្យសុំជំនួយសាច់ប្រាក់ ហើយស្ថិតក្នុងផ្នែកណាមួយខាងក្រោម

រដ្ឋនឹងមិនរក្សាទុកថ្លៃចិញ្ចឹមណាមួយសម្រាប់កូនរបស់អ្នកទេ៖

- កម្មវិធី SFPSS
- JOBS Plus
- គ្រួសារដែលមានឪពុកម្ដាយពីរនាក់

នៅពេលដែលយើងកំណត់សិទ្ធិ និងជំនួយរបស់អ្នក នោះចំនួនទឹកប្រាក់ នៃថ្លៃចិញ្ចឹមកូនបច្ចុប្បន្ន $50 ក្នុងកូនមួយ ក្នុងមួយខែ រហូតដល់ $200 ក្នុងមួយគ្រួសារ ក្នុងមួយខែ នឹងមិនរាប់បញ្ចូលទៅក្នុងប្រាក់ចំណូលប្រចាំខែរបស់អ្នកទេ។

នៅពេលអ្នកឈប់ទទួលជំនួយពីកម្មវិធីជំនួយសាច់ប្រាក់៖

- ការបង់ថ្លៃចិញ្ចឹមកូននាពេលបច្ចុប្បន្ននឹងបានទៅដល់អ្នក។
- រដ្ឋនឹងរក្សាទុកនូវថ្លៃចិញ្ចឹមកូនដែលជំពាក់សម្រាប់ខែណាដែលអ្នកបានទទួលជំនួយសាច់ប្រាក់។
- អ្នកប្រហែលជាអាចរក្សាបាននូវថ្លៃចិញ្ចឹមកូនដែលជំពាក់សម្រាប់ខែណាដែលអ្នកមិនបានទទួលជំនួយជាសាច់ប្រាក់ពីរដ្ឋ។

ធ្វើការជាមួយកម្មវិធីចេញថ្លៃចិញ្ចឹមកូន

ខណៈពេលដែលអ្នកកំពុងទទួលបានជំនួយសាច់ប្រាក់ អ្នកនឹងត្រូវធ្វើការជាមួយកម្មវិធីគ្រប់គ្រងនូវការចេញថ្លៃចិញ្ចឹមកូនពីរដ្ឋ។

**ការសំខាន់៖** អ្នកមិនចាំបាច់ធ្វើការជាមួយកម្មវិធីចេញថ្លៃចិញ្ចឹមកូនទេ ប្រសិនបើអ្នកគិតថាការទារថ្លៃចិញ្ចឹមកូននឹងបង្កគ្រោះថ្នាក់ដល់អ្នក ឬកូនរបស់អ្នក។

ការធ្វើការជាមួយកម្មវិធីចេញថ្លៃចិញ្ចឹមកូនអាចមានន័យថាអ្នកធ្វើដូចខាងក្រោម៖

- ជួយស្វែងរកឪពុកម្តាយផ្សេងទៀតរបស់កូនអ្នក។
- ប្រាប់ឈ្មោះពេញតាមផ្លូវច្បាប់របស់ឪពុករបស់កុមារ (ដើម្បីបង្កើតភាពជាឪពុក) ។
- ទទួលបានដីកាចេញថ្លៃចិញ្ចឹមកូន។

**ព័ត៌មានអំពីជំនួយផ្នែកពេទ្យ**

សូមអានព័ត៌មាននេះដោយយកចិត្តទុកដាក់

ព័ត៌មានដែលអ្នកផ្តល់អោយនៅលើបែបបទនេះនឹងត្រូវបានគេយកទៅពិនិត្យ និងផ្ទៀងផ្ទាត់ជាមួយមន្ត្រីសហព័ន្ធ រដ្ឋ និងក្នុងតំបន់។ នៅពេលដែលយើងកំណត់សិទ្ធិរបស់អ្នកសម្រាប់ជំនួយផ្នែកពេទ្យ DHS និង OHA ប្រើវិធីដូចខាងក្រោម៖

- ប្រព័ន្ធផ្ទៀងផ្ទាត់ប្រាក់ចំណូល និងសិទ្ធិទទួលបាន (IEVS)
- ប្រព័ន្ធផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិ (AVS)

AVS ស្វែងរកនូវព័ត៌មានខាងក្រោមអំពីរូបអ្នក និងសមាជិកគ្រួសារដែលតម្រូវឱ្យផ្តល់នូវព័ត៌មានហិរញ្ញវត្ថុ នៅពេលដែលអ្នកដាក់ពាក្យសុំ និងទទួលជំនួយផ្នែកពេទ្យ។ AVS ស្វែងរកពត៌មានខាងក្រោម ថាតើអ្នករាយការណ៍វាដែរឬអត់។

- ពីគ្រឹះស្ថានហិរញ្ញវត្ថុនានា
    - គណនីធនាគារទាំងអស់
    - គណនីធនាគារសហជីពឥណទានទាំងអស់
- កំណត់ត្រាអចលនទ្រព្យដែលមាន
    - ផ្ទះសម្បែង
    - ដីធ្លី
        - កំណត់ត្រាយានយន្ត
            - យានជំនិះ

ប្តីប្រពន្ធស្របច្បាប់ត្រូវតែផ្តល់នូវព័ត៌មានហិរញ្ញវត្ថុ។ DHS និង OHA ក៏ប្រហែលជាអាចផ្តល់នូវព័ត៌មានណាមួយអំពីពាក្យសុំរបស់អ្នកទៅអោយមន្ត្រីអនុវត្តច្បាប់ ដើម្បីជួយពួកគេអោយចាប់ខ្លួននរណាម្នាក់ដែលរត់គេចចេញពីសំណាញ់ច្បាប់។

ការចាត់តាំងនូវការចេញថ្លៃ និងថ្លៃជំពាក់

ដើម្បីមានលក្ខណៈសម្បត្តិគ្រប់គ្រាន់សម្រាប់ទទួលជំនួយផ្នែកពេទ្យ អ្នកត្រូវតែអនុញ្ញាតឱ្យ DHS, OHA និង CCO មានពត៌មានអំពីលុយកាក់របស់អ្នកមានដែល៖

- អ្នក ឬអ្នកផ្សេងទៀតដែលទទួលជំនួយផ្នែកពេទ្យជាមួយអ្នក ទទួល ឬមានសិទ្ធិទទួលបានពីអ្នកដែលត្រូវទទួលខុសត្រូវតាមផ្លូវច្បាប់សម្រាប់សំណងរបួសស្នាម ឬចេញថ្លៃព្យាបាលដែលបង់ដោយជំនួយផ្នែកពេទ្យ។

នេះរួមបញ្ចូលទាំងប្រាក់ដែលបានមកពីអ្វីមួយដូចខាងក្រោម៖

- ក្រុមហ៊ុនធានារ៉ាប់រងសុខភាពឯកជន
- ក្រុមហ៊ុនធានារ៉ាប់រងរថយន្ត
- ជនណាម្នាក់
- ប្រភពផ្សេងទៀត។

នេះត្រូវបានគេហៅថា "ការចាត់តាំងនូវការចេញថ្លៃ" ទៅ DHS ឬ OHA និង CCO ។ ការចាត់តាំងនូវការចេញថ្លៃគឺធ្វើឡើងដោយស្វ័យប្រវត្តិសម្រាប់អ្នកដែលទទួលជំនួយផ្នែកពេទ្យ។ ដើម្បីបន្តទទួលបានជំនួយផ្នែកពេទ្យ អ្នក និងសមាជិកគ្រួសារផ្សេងទៀត (ដែលរាប់បញ្ចូលទាំងកូនដែលនឹងកើត) ត្រូវតែជួយ DHS ឬ OHA ស្វែងរក និងទទួលបានការចេញថ្លៃទាំងនេះតាមវិធីខាងក្រោមទាំងអស់៖

- ប្រាប់ DHS, OHA និង CCO របស់អ្នកអំពីភាគីទីបីដែលធ្វើឱ្យអ្នក ឬសមាជិកគ្រួសាររបស់អ្នករងរបួសស្នាម ក្នុងរយៈពេល 10 ថ្ងៃ។
- ផ្តល់ព័ត៌មានអំពីភាគីដែលបណ្តាលឱ្យអ្នករងរបួស។
- ជួយផ្តល់នូវព័ត៌មានផ្សេងទៀតដែលបានស្នើសុំ។ នេះរួមបញ្ចូលទាំងព័ត៌មានធានារ៉ាប់រង។ មានដែនកំណត់លើប្រាក់ដែល

DHS ឬ OHA ដែលអាចទទួលយកបាន។

វាមិនអាចលើសពីចំនួនដែលបានបង់សម្រាប់ថ្លៃព្យាបាលដែលភាគីសំណាងចេញអោយនោះទេ។ ប្រសិនបើអ្នកបានទទួលជំនួយ TANF អ្នកប្រហែលជាត្រូវសងប្រាក់វិញផងដែរ។ សូមមើលផ្នែកព័ត៌មានអំពីជំនួយសាច់ប្រាក់។

យើងអាចដាក់បំណុលសម្រាប់ប្រាក់ណាមួយដែលត្រូវបង់ដោយភាគីដែលទទួលខុសត្រូវស្របច្បាប់ដើម្បីប្រាកដថា DHS, OHA ឬ CCO ទទួលបានការចេញថ្លៃនោះ។

## ការចេញផ្សាយនូវព័ត៌មាន

អ្នកត្រូវតែយល់ព្រមថាពត៌មានខាងក្រោមនេះអាចចេញផ្សាយកំណត់ត្រាពេទ្យដល់ក្រុមហ៊ុនធានារ៉ាប់រងនានាបាន៖

- ឈ្មោះពេទ្យផ្តល់សេវាកម្ម
- ឈ្មោះមន្ទីរពេទ្យ
- ឈ្មោះនិយោជក
- ភ្នាក់ងាររដ្ឋាភិបាលនានា

វាគ្របដណ្តប់កំណត់ត្រាអំពីរូបអ្នក និងសមាជិកគ្រួសារផ្សេងទៀតដែលទទួលជំនួយផ្នែកពេទ្យ។ វានឹងត្រូវតែធ្វើដូច្នេះដើម្បីអោយ DHS ឬ OHA នឹងទទួលបានប្រាក់ត្រឡប់មកវិញ។

## ប្រសិនបើអ្នកមានការធានារ៉ាប់រងផ្សេងទៀត

ប្រសិនបើអ្នក ឬសមាជិកគ្រួសាររបស់អ្នកមានធានារ៉ាប់រងផ្នែកពេទ្យផ្សេងទៀត សូមប្រាប់ទៅអ្នកផ្តល់សេវា (ដូចជាវេជ្ជបណ្ឌិត គ្លីនិក ឱសថស្ថាន ឬមន្ទីរពេទ្យ) មុនពេលដែលអ្នកទទួលនូវសេវាកម្ម។ ប្រសិនបើអ្នកមានធានារ៉ាប់រងលើយានយន្ត ហើយត្រូវបានរងរបួសក្នុងគ្រោះថ្នាក់ចរាចរណ៍ សូមប្រាប់អ្នកផ្តល់សេវាអំពីពត៌មានធានារ៉ាប់រងយានយន្តរបស់អ្នកផង។ ពួកគេត្រូវតែចេញវិក្កយបត្រទៅក្រុមហ៊ុនធានារ៉ាប់រងជាមុនសិន មុនពេលពួកគេចេញវិក្កយបត្រទៅ OHA។ ប្រសិនបើ DHS ឬ OHA បង់វិក្កយបត្រពេទ្យ ដែលគួរតែត្រូវបានបង់ដោយក្រុមហ៊ុនធានារ៉ាប់រង នោះ DHS ឬ OHA នឹងទារប្រាក់នោះមកវិញ។ ឧទាហរណ៍៖

- ប្រសិនបើ DHS ឬ OHA ចេញថ្លៃបង់វិក្កយបត្រដែលធានារ៉ាប់រងឯកជនមួយគួរតែជាអ្នកចេញថ្លៃបង់នោះ DHS ឬ OHA នឹងព្យាយាមទារប្រាក់នោះពីក្រុមហ៊ុនធានារ៉ាប់រងមកវិញ។
- ប្រសិនបើ DHS ឬ OHA ចេញថ្លៃបង់វិក្កយបត្រពេទ្យ ហើយពេទ្យផ្តល់សេវាក៏ទទួលបានប្រាក់ពីក្រុមហ៊ុនធានារ៉ាប់រងដែរ នោះDHS ឬ OHA នឹងព្យាយាមទារប្រាក់របស់ខ្លួនមកវិញពីពេទ្យផ្តល់សេវាកម្មនោះ។

- ប្រសិនបើ DHS ឬ OHA ចេញថ្លៃបង់វិក្កយបត្រពេទ្យ ហើយក្រុមហ៊ុនធានារ៉ាប់រងផ្ញើឱ្យអ្នកនូវមូលប្បទានប័ត្រសម្រាប់សំណងនោះ អញ្ចឹង DHS ឬ OHA នឹងព្យាយាមទារប្រាក់របស់ខ្លួនពីអ្នកមកវិញ។

កម្មវិធីទារសំណងពីអចលនទ្រព្យ

កម្មវិធីទារសំណងពីអចលនៈទ្រព្យ គឺជាកម្មវិធីស្មុគស្មាញដែលអនុវត្តចំពោះរឿងដូចខាងក្រោម៖

- ជំនួយផ្នែកពេទ្យ
- ជំនួយទូទៅ
- កម្មវិធីផ្តល់ប្រាក់ចំណូលបន្ថែមក្នុងរដ្ឋអូរិហ្គិន
- មនុស្សមួយចំនួនដែលបានទទួលទាំងជំនួយមេឌីឃែរ និង ជំនួយផ្នែកពេទ្យក្នុងពេលតែមួយ

គោលបំណងនៃការទារសំណងពីអចលនទ្រព្យគឺដើម្បីស្វែងរកការសងបំណុលដែលជាទ្រព្យសម្បត្តិរបស់អ្នកទទួលជំនួយដែលគាត់បានស្លាប់ទៅហើយ។ លុយមួយចំនួនត្រូវត្រលប់ទៅរដ្ឋាភិបាលសហព័ន្ធវិញ។ លុយនៅសល់ក្នុងកម្មវិធីគឺផ្តល់ជាមូលនិធិសម្រាប់មនុស្សផ្សេងទៀតដែលត្រូវការជំនួយ។ មានករណីលើកលែងជាច្រើនចំពោះការទារសំណងពីអចលនទ្រព្យមកវិញ។

សិទ្ធិរបស់រដ្ឋក្នុងការទារសំណងជំនួយពីអចលនទ្រព្យរបស់អ្នក។

**DHS និង OHA អាចទារសំណងប្រាក់** ពីអចលនទ្រព្យរបស់អ្នក (ដូចដែលបានកំណត់ក្នុងច្បាប់ ORS 416.350) បន្ទាប់ពីអ្នកស្លាប់ ប្រសិនបើអ្នកមានស្ថានភាពដូចខាងក្រោម។

- ប្រសិនបើករណីខាងក្រោមកើតឡើង ចំនួនទឹកប្រាក់នៃជំនួយផ្នែកពេទ្យប្រហែលជាអាចត្រូវបានកាត់កងពីអចលនទ្រព្យរបស់អ្នក៖
    - អ្នកទទួលបានជំនួយផ្នែកពេទ្យរបស់រដ្ឋ ក្រោយពីថ្ងៃទី 1 ខែតុលា ឆ្នាំ 2013។
    - អ្នកមានអាយុលើសពី 54 ឆ្នាំ ហើយកំពុងទទួលបានជំនួយមើលថែរយៈពេលវែង។

  នេះរាប់បញ្ចូលទាំងជំនួយពីគម្រោងសុខភាពនៃរដ្ឋអូរិហ្គិន ដែលបានចេញ ក្នុងនាមគម្រោងកិច្ចគាំពារដែលមានការចាត់ចែង ឬការបង់ប្រាក់ទៅអោយ CCO ។
- ប្រសិនបើករណីខាងក្រោមកើតឡើង ចំនួនទឹកប្រាក់នៃជំនួយផ្នែកពេទ្យប្រហែលជាអាចត្រូវបានកាត់កងពីអចលនទ្រព្យរបស់អ្នក៖
    - អ្នកទទួលបានជំនួយផ្នែកពេទ្យរបស់រដ្ឋ ក្រោយពីថ្ងៃទី 1 ខែតុលា ឆ្នាំ 2013។

- អ្នកមានអាយុលើសពី 54 ឆ្នាំ ឬអ្នកមានលុយក្នុងគណនី trust ប្រភេទមួយចំនួន៖
    - គណនី trust ដែលត្រូវការជាពិសេស
    - គណនី trust ដែលជាប្រាក់ចំណូល
- ប្រសិនបើអ្នកទទួលបានជំនួយតាមរយៈវិធីណាមួយខាងក្រោម នោះអាចនឹងមានការទាមទារសំណងពីអចលនទ្រព្យរបស់អ្នក៖
    - កម្មវិធីផ្តល់ប្រាក់ចំណូលបន្ថែមក្នុងរដ្ឋអូរិហ្គិន
    - ជំនួយទូទៅជាក់លាក់
    - រដ្ឋត្រូវបានតម្រូវឱ្យបង់ថ្លៃជំនួយប្រចាំខែសម្រាប់រូបអ្នក ដោយសារអ្នកទទួលបានទាំងជំនួយផ្នែកពេទ្យ និងជំនួយមេឌីឃែរផ្នែក D ។

DHS និង OHA នឹងពន្យាពេលទារសំណង ប្រសិនបើប្តីឬប្រពន្ធរបស់អ្នកនៅរស់រានមានជីវិតនៅឡើយ។

## DHS និង OHA មិនទាមទារសំណងពីអចលនទ្រព្យរបស់អ្នកទេ

ប្រសិនបើមានសមាជិកណាមួយខាងក្រោមនៃគ្រួសាររបស់អ្នកនៅមានជីវិត៖

- កូនបង្កើត ឬកូនចិញ្ចឹមរបស់អ្នកមានអាយុក្រោម 21 ឆ្នាំ។ ចំណាំ៖ នេះមិនរាប់បញ្ចូលនូវកូនចុងឬកូនដើមទេ។
- កូនបង្កើត ឬកូនចិញ្ចឹមរបស់អ្នក គ្រប់វ័យ ដែលមានពិការភ្នែក ឬពិការភាពដូចដែលបានកំណត់ដោយលក្ខណៈវិនិច្ឆ័យពីសន្តិសុខសង្គម ។

**ចំណាំ**: ច្បាប់ និងវិធានអំពីការទាមទារសំណងពីអចលនទ្រព្យអាចផ្លាស់ប្តូរបានដោយគ្មានការជូនដំណឹងទុកជាមុន។

បុគ្គលណាម្នាក់ដែលទទួលបានកេរ្តិ៍ទ្រព្យសម្បត្តិពីអចលនវត្ថុរបស់អ្នកទទួលជំនួយ អាចស្នើសុំឱ្យ DHS ឬ OHA លើកលែងការទារសំណងពីអចលនទ្រព្យបាន ប្រសិនបើពួកគេបំពេញតាមតម្រូវការដោយសារមានភាពលំបាកវេទនា។ សេចក្តីណែនាំអំពីរបៀបស្នើសុំការលើកលែងទារសំណងដោយសារមានការលំបាកវេទនាគឺមាននៅក្នុងព័ត៌មានដែលអង្គភាពរដ្ឋបាលអចលនវត្ថុផ្ញើមកនៅពេលដែលគេចាប់ផ្តើមដំណើរការទារសំណងឡើងវិញ។

ព័ត៌មានទំនាក់ទំនងសម្រាប់អង្គភាពរដ្ឋបាលអចលនៈទ្រព្យមានដូចខាងក្រោម៖

Estate Administration Unit PO

Box 14021

Salem, OR 97309-5024

503-378-2884

1-800-826-5675 (នៅក្នុងរដ្ឋអូរិហ្គិនតែប៉ុណ្ណោះ)

ទូរសារលេខ៖ 503-378-3137

**ដែនកំណត់ពេលវេលា**

**ដែនកំណត់ពេលវេលាជំនួយ TANF**

រដ្ឋអូរិហ្គិនមានពេលវេលាកំណត់រយៈពេលប្រាំឆ្នាំ ដើម្បីទទួលបានជំនួយ TANF ។

សូមនិយាយជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នក អំពីរបៀបដែលវាអាចប៉ះពាល់ដល់អ្នក។

**ដែនកំណត់ពេលវេលាជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន**

ដែនកំណត់ពេលវេលាអតិបរមាដែលអនុញ្ញាតទទួលជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួនគឺប្រាំបីខែ គិតចាប់ពីពេលដូចខាងក្រោម៖

- អ្នកបានចូលមករស់នៅក្នុងប្រទេសអាមេរិក។
- អ្នកបានទទួលស្ថានភាពអន្តោប្រវេសន៍របស់អ្នក។

សូមនិយាយជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នក អំពីរបៀបដែលវាអាចប៉ះពាល់ដល់អ្នក។

**ដែនកំណត់ពេលវេលាពីកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP)**

ដែនកំណត់ពេលវេលាដើម្បីទទួលបានជំនួយ SNAP គឺបីខែពេញក្នុងរយៈពេលបីឆ្នាំសម្រាប់ខាងក្រោម៖

- មនុស្សពេញវ័យដែលមានសមត្ថភាពធ្វើការ ដោយគ្មានអ្នកក្នុងបន្ទុក

បើមិនដូច្នេះទេ មានតម្រូវការការងារ។ ចូរនិយាយជាមួយបុគ្គលិកកាន់សំណុំរឿងរបស់អ្នកអំពីរបៀបដែលវាអាចប៉ះពាល់ដល់អ្នក។

## របាយការណ៍នូវការផ្លាស់ប្ដូរ

ប្រសិនបើអ្នកទទួលបានជំនួយពី DHS ឬ OHA អ្នកត្រូវតែរាយការណ៍អំពីការផ្លាស់ប្ដូរមួយចំនួនដែលប៉ះពាល់ដល់អ្នក និងអ្នកផ្សេងទៀត ដែលទទួលបានជំនួយជាមួយអ្នក។ ប្រសិនបើអ្នកមិនរាយការណ៍នូវការផ្លាស់ប្ដូរតាមតម្រូវការនោះទេ អ្នកអាចទទួលបានជំនួយច្រើនពេក។ មាននរណាម្នាក់នៅក្នុងផ្ទះរបស់អ្នកដែលមានអាយុ 18 ឆ្នាំឬចាស់ជាងនេះ អាចត្រូវបានស្នើសុំឱ្យសងជំនួយ។

នៅពេលដែលត្រូវបានអនុម័តសម្រាប់ជំនួយ សំបុត្រជូនដំណឹង ប្រាប់អ្នកពីអ្វីដែលអ្នកត្រូវរាយការណ៍ និងត្រូវរាយការណ៍នៅពេលណា។ កម្មវិធីនីមួយៗមានតម្រូវការរាយការណ៍ខុសៗគ្នា។ អ្វីដែលអ្នកត្រូវរាយការណ៍ និងពេលណាត្រូវរាយការណ៍ក៏អាចខុសគ្នាដែរ។ នៅពេលអ្នករាយការណ៍អំពីការផ្លាស់ប្ដូរ បុគ្គលិកក្រសួងនឹងប្រាប់អ្នកប្រសិនបើអ្នកត្រូវការផ្ដល់នូវភស្តុតាងអ្វីមួយ។ ប្រសិនបើការផ្លាស់ប្ដូរនោះប៉ះពាល់ដល់ជំនួយផ្សេងទៀតដែលអ្នកទទួលបាន បុគ្គលិកយើងនឹងប្រាប់អ្នកឱ្យដឹង។ ប្រសិនបើអ្នកមិនប្រាកដថាតើអ្នកត្រូវការរាយការណ៍នូវការផ្លាស់ប្ដូរអ្វីទេ អ្នកអាចសួរទៅបុគ្គលិកយើងបាន។

## ការដាក់ពិន័យ

### ព័ត៌មានអំពីការពិន័យពីកម្មវិធីជំនួយសាច់ប្រាក់

ប្រសិនបើអ្នកធ្វើដោយចេតនាណាមួយដូចខាងក្រោម ដើម្បីទទួលបានជំនួយបណ្ដោះអាសន្នសម្រាប់គ្រួសារដែលខ្វះខាត (TANF) ឬជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន (RCA) នោះមានការពិន័យដូចតទៅ៖

- ផ្ដល់នូវព័ត៌មានមិនពិតអំពីអ្នក ឬនរណាម្នាក់ដែលអ្នកដាក់ពាក្យសុំជំនួយ។
- លាក់ព័ត៌មានអំពីអ្នក ឬនរណាម្នាក់ដែលអ្នកដាក់ពាក្យសុំជំនួយ។
- ផ្ដល់ព័ត៌មានមិនពិតអំពីទីកន្លែងដែលអ្នករស់នៅ។

នេះជាអ្វីដែលនឹងកើតឡើង ប្រសិនបើអ្នកធ្វើរឿងណាមួយខាងលើ៖

- លើកដំបូងអ្នកនឹងមិនទទួលបានជំនួយ TANF ក្នុងរយៈពេល 12 ខែ។
- លើកទីពីរ អ្នកនឹងមិនអាចទទួលបានជំនួយ TANF ក្នុងរយៈពេល 24 ខែ។
- លើកទីបី អ្នកនឹងមិនអាចទទួលបានជំនួយ TANF ទាល់តែសោះ។
- អ្នកនឹងត្រូវសងត្រលប់មកវិញនូវជំនួយ TANF ទាំងឡាយណាដែលអ្នកមិនគួរទទួលបាន។
- ជំនួយម្ហូបអាហាររបស់អ្នកនឹងមិនកើនឡើងទេ ទោះបីជាអ្នកទទួលបានជំនួយ TANF តិចជាងមុនក៏ដោយ។

នៅក្នុងកម្មវិធី TA-DVS ប្រសិនបើអ្នកធ្វើដោយចេតនានូវរឿងណាមួយដូចខាងក្រោម អ្នកអាចប្រឈមមុខនឹងការផាកពិន័យ ដូចជា៖

- ផ្តល់នូវព័ត៌មានមិនពិតអំពីការមើលថែ និងចិញ្ចឹមកូនរបស់អ្នក។
- ផ្តល់នូវព័ត៌មានមិនពិតអំពីការរស់នៅក្នុងរដ្ឋអូរីហ្គិន។

**ព័ត៌មានអំពីការផាកពិន័យពីកម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP)**

| **ប្រសិនបើអ្នកធ្វើរឿងដូចខាងក្រោម៖** | **អ្នកនឹងបាត់បង់ជំនួយម្ហូបអាហារសម្រាប់រយៈពេល ដែង៖** |
|---|---|
| • លាក់បំបាំងព័ត៌មាន ឬផ្តល់សេចក្តីថ្លែងការណ៍មិនពិត។<br>• ប្រើកាតលុយជំនួយ (EBT) ដែលជាកម្មសិទ្ធិរបស់អ្នកផ្សេង។<br>• ប្រើជំនួយម្ហូបអាហារយកទៅទិញស្រា ឬថ្នាំជក់។<br>• ជួញដូរ ឬលក់ជំនួយ ឬកាត EBT ។<br>• យកកាតទៅចាយទិញរបស់របរ ហើយដូរជាសាច់ប្រាក់វិញ។<br>• លក់អាហារដែលបានទិញដោយកាតជំនួយអាហារទៅប្តូរជាសាច់ប្រាក់។ | • 12 ខែសម្រាប់បទល្មើសដំបូង<br>• 24 ខែសម្រាប់បទល្មើសលើកទីពីរ<br>• ផ្តាច់ជាអចិន្ត្រៃយ៍ចំពោះបទល្មើសលើកទីបី |
| • លក់ដូរជំនួយអាហារសម្រាប់សារធាតុញៀនដូចជាថ្នាំញៀនជាដើម។ | • 24 ខែសម្រាប់បទល្មើសដំបូង<br>• ផ្តាច់ជាអចិន្ត្រៃយ៍សម្រាប់បទល្មើសលើកទីពីរ |
| • ជួញដូរជំនួយអាហារសម្រាប់អាវុធ គ្រាប់រំសេវ ឬគ្រឿងផ្ទុះ។ | • ផ្តាច់ជាអចិន្ត្រៃយ៍ |
| • ជួញដូរ ទិញ ឬលក់ជំនួយអាហារចាប់ពី 500 ដុល្លារ ឬច្រើនជាងនេះ។ | • ផ្តាច់ជាអចិន្ត្រៃយ៍ |
| • ផ្តល់ព័ត៌មានមិនពិតអំពីអ្នកជានរណា ឬកន្លែងដែលអ្នករស់នៅ ដើម្បីអោយអ្នកអាចទទួលបានជំនួយអាហារបន្ថែម។ | • 10 ឆ្នាំសម្រាប់បទល្មើសនីមួយៗ |

អ្នកក៏ប្រហែលជាអាចទទួលនូវការផាកពិនិយដូចខាងក្រោម៖

- ទទួលបានការផាកពិន័យរហូតដល់ 250,000 ដុល្លារ
- ដាក់ពន្ធនាគាររហូតដល់ ២០ ឆ្នាំ
- ទទួលការចោទប្រកាន់ក្រោមច្បាប់សហព័ន្ធ

| **បើអ្នកដឹងហើយធ្វើរឿងដូចខាងក្រោម៖** | **អ្នកប្រហែលជាអាចស្ថិតក្នុងស្ថានភាពដូចនៅក្រោម៖** |
|---|---|
| • ប្រើកាត EBT ដែលមិនមែនជារបស់អ្នក។<br>• ផ្ទេរកាត EBT របស់អ្នកទៅអោយមនុស្សផ្សេងទៀត។<br>• ទទួលបាន ឬមានកាត EBT ដែលមិនមែនជារបស់អ្នក។ | • ត្រូវបានរកឃើញថាមានទោសបទឧក្រិដ្ឋ ឬបទមជ្ឈិម។<br>• ទទួលការផាកពិន័យ។<br>• ដាក់គុក។<br>• មិនមានសិទ្ធិទទួលបានជំនួយអាហារក្នុងមួយពេល។ |

**ពិន័យចំពោះការផ្ទេរទ្រព្យសម្បត្តិ**

អ្នកប្រហែលជាអាចមិនមានសិទ្ធិទទួលបានជំនួយមួយចំនួន ប្រសិនបើអ្នកផ្ទេរទ្រព្យដែលមានក្នុងតម្លៃតិចជាងតម្លៃរបស់វា។ នៅពេលដែលអ្នកប្រគល់ ឬលក់ទ្រព្យសម្បត្តិ យើងនិយាយថាអ្នកផ្ទេរទ្រព្យសម្បត្តិនោះ។ ទ្រព្យសកម្មគឺជាប្រាក់ចំណូល និងរាប់ជាវត្ថុមានតម្លៃ។ ឧទាហរណ៍មានដូចខាងក្រោម៖

- ផ្ទះសម្បែង
- ដីធ្លី ផ្ទះសម្បែង
- យានជំនិះ
- លុយ

សូមពិភាក្សាជាមួយបុគ្គលិកក្រសួងរបស់អ្នកមុនពេលអ្នកលក់ ឬប្រគល់ទ្រព្យសម្បត្តិ។

ប្រសិនបើអ្នកផ្ទេរទ្រព្យសម្បត្តិ អ្នកប្រហែលជាមិនមានសិទ្ធិទទួលបានជំនួយខាងក្រោមទេ៖

- សេវាកម្មមើលថែរយៈពេលវែង (LTC)៖
  - មណ្ឌលមើលថែមនុស្សពេញវ័យ
  - មណ្ឌលរស់នៅដែលមានគេមើលថែ
  - សេវាកម្មមើលថែតាមផ្ទះ
  - កន្លែងមើលថែមនុស្សចាស់ និងជនពិការ
  - កន្លែងមើលថែទាំផ្សេងទៀត
- ជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន

- ជំនួយពេទ្យសំរាប់ជនភៀសខ្លួន
- កម្មវិធីជំនួយអាហារូបត្ថម្ភបន្ថែម (SNAP) ដែលជាជំនួយអាហារ
- ជំនួយបណ្តោះអាសន្នសម្រាប់គ្រួសារដែលខ្វះខាត (TANF) ដែលជាជំនួយសាច់ប្រាក់។

យើងមើលទៅក្រោយមុនពេលដែលអ្នកបានដាក់ពាក្យ ដើម្បីមើលថាតើមានការផ្ទេរទ្រព្យសម្បត្តិណាមួយដែលនាំឱ្យមានការពិន័យដែរទេ។

- សម្រាប់ជំនួយ LTC យើងមើលបកក្រោយ 5 ឆ្នាំមុន។
- សម្រាប់ជំនួយ TANF យើងមើលបកក្រោយ ៣ ឆ្នាំមុន។
- សម្រាប់ជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន និងជំនួយពេទ្យសំរាប់ជនភៀសខ្លួន យើងមើលបកក្រោយ ៣ ឆ្នាំមុន។
- សម្រាប់ជំនួយ SNAP យើងមើលបកក្រោយ 3 ខែមុន។

ការពិន័យសម្រាប់ការផ្ទេរទ្រព្យសម្បត្តិចាប់ផ្តើមនៅពេលដែលអ្នកដាក់ពាក្យ ហើយនឹងមានសិទ្ធិទទួលជំនួយ។ ការពិន័យនឹងអនុវត្តចំពោះតែជំនួយដែលបានរាយខាងលើប៉ុណ្ណោះ។ ការពិន័យគឺយើងនឹងបដិសេធនូវសំណើសុំជំនួយរបស់អ្នកនោះ។ ប្រសិនបើអ្នកផ្ទេរទ្រព្យសម្បត្តិ ខណៈពេលដែលអ្នកទទួលបានជំនួយ នោះក៏នឹងត្រូវផាកពិន័យផងដែរ។ ការពិន័យនឹងបញ្ឈប់ជំនួយនោះមួយរយៈ។ ប្រសិនបើជំនួយ LTC របស់អ្នកបញ្ចប់ វាអាចកាត់បន្ថយ ឬផ្តាច់ជំនួយពេទ្យផ្សេងទៀតរបស់អ្នកបាន។

## ព័ត៌មានសម្រាប់កម្មវិធីទាំងអស់

គោលនយោបាយមិនរើសអើងរបស់យើង

ក្រសួងសង្គមកិច្ច (DHS) និងអាជ្ញាធរសុខភាពរដ្ឋអូរ៉េហ្គិន (OHA) មិនរើសអើងនរណាម្នាក់ឡើយ។ នេះមានន័យថា DHS និង OHA នឹងជួយអ្នកទាំងឡាយណាដែលមានលក្ខណៈសម្បត្តិគ្រប់គ្រាន់។ DHS និង OHA នឹងមិនរើសអើងចំពោះនរណាម្នាក់ខុសពីគ្នា ដោយសារតែការណាមួយដូចខាងក្រោម នោះទេ៖

- អាយុ
- ពូជសាសន៍
- ពណ៌សម្បុរ
- ដើមកំណើត

- ភេទ
- សាសនា
- ជំនឿនយោបាយ*
- ពិការភាព
- ជម្រើសផ្លូវភេទ†
- ស្ថានភាពគ្រួសារ ‡

អ្នកប្រហែលជាអាចដាក់ពាក្យបណ្តឹងតវ៉ាបាន ប្រសិនបើអ្នកជឿថា DHS ឬ OHA បានរើសអើងអ្នកតាមហេតុផលដែលមានសរសេរទាំងនេះ។ ដើម្បីដាក់ពាក្យបណ្តឹង អ្នកអាចទូរស័ព្ទ ឬសរសេរសំបុត្រតវ៉ាទៅការិយាល័យផ្តល់ដំបូន្មានដល់ចាហ្វាយរដ្ឋ៖

Governor's Advocacy Office 500

Summer Street NE, E17 Salem,

OR 97301

503-945-6904

1-800-442-5238

TTY 711

អ៊ីមែល៖ DHS.info@dhsoha.state.or.us

**ឱកាសស្មើគ្នាគឺជាច្បាប់!**

យើងធ្វើការជាមួយក្រសួងកសិកម្មនៃសហរដ្ឋអាមេរិក (USDA) និងក្រសួងសុខាភិបាល និងសង្គមកិច្ចនៃសហរដ្ឋអាមេរិក (HHS)។ ក្រសួងទាំងពីរជាកន្លែង និងជានិយោជកដែលផ្តល់ឱកាសអោយស្មើៗគ្នា ។ ជំនួយ និងសេវាកម្មផ្សេងទៀតមានផ្តល់ជូនតាមសំណើសម្រាប់បុគ្គលដែលមានពិការភាព។

ដើម្បីដាក់ពាក្យបណ្តឹងជាមួយ USDA និង HHS សូមអានបែបបទ "ព័ត៌មានស្តីពីបណ្តឹងលើការរើសអើងអតិថិជន" ( DHS

9001 )។ អ្នកអាចរកឃើញបែបបទនេះនៅក្នុង "ព័ត៌មាន និងសំណុំឯកសារយោង" ( DHS 6609 )។

* អតិថិជន SNAP មានការការពារពីការរើសអើងជំនឿនយោបាយ។

†ជម្រើសផ្លូវភេទមានការការពារពីរដ្ឋ ប៉ុន្តែមិនការពារពីច្បាប់សហព័ន្ធទេ។

‡អតិថិជនដែលទទួលជំនួយផ្នែកពេទ្យមានការការពារពីការរើសអើងនៃស្ថានភាពគ្រួសារ។

**ហេតុអ្វីបានជាយើងត្រូវការលេខសន្តិសុខសង្គមរបស់អ្នក**

ខាងក្រោមតម្រូវឱ្យអ្នកណាម្នាក់ដែលដាក់ពាក្យសុំជំនួយសាច់ប្រាក់ ឬម្ហូបអាហារ ត្រូវផ្តល់ឱ្យ DHS និង OHA នូវលេខសន្តិសុខសង្គម (SSN) របស់ពួកគេ៖

- ច្បាប់សហព័ន្ធ (42 USC 1320b-7(a) និង (b), 7 USC 2011-2036, 42 CFR 435.910, 42 CFR 435.920 និង 42 CFR 457.340(b))
- ច្បាប់រដ្ឋបាលនៃរដ្ឋអូរិហ្គិន (OAR 461-120-0210)

ប្រសិនបើអ្នកផ្តល់លេខ SSN វាអាចបង្កើនល្បឿនដំណើរការសុំជំនួយពីកម្មវិធីអោយបានលឿន។ ប្រសិនបើនរណាម្នាក់មិនមានលេខ SSN ទេ សូមចូលទៅមើលវិបសាយ www.ssa.gov សម្រាប់ព័ត៌មានអំពីរបៀបដាក់ពាក្យសុំជំនួយ។

- DHS និង OHA នឹងប្រើប្រាស់លេខ SSN របស់អ្នក ដើម្បីជួយសម្រេចចិត្តថាតើអ្នកមានសិទ្ធិទទួលបានជំនួយដែរឬទេ។ យើងនឹងប្រើលេខ SSN របស់អ្នកដើម្បីការងារដូចខាងក្រោម៖
  - ផ្ទៀងផ្ទាត់ប្រាក់ចំណូលរបស់អ្នក
  - ផ្ទៀងផ្ទាត់ទ្រព្យសម្បត្តិផ្សេងទៀត
  - ផ្គូផ្គងកំណត់ត្រារដ្ឋ និងសហព័ន្ធផ្សេងទៀតជាមួយក្រសួងដូចជា៖
    - ក្រសួងពន្ធដារ (IRS)
    - ជំនួយមេឌីខេដ
    - ក្រសួងមើលការខុសត្រូវកើការចេញថ្លៃចិញ្ចឹមកូន
    - រដ្ឋបាលសន្តិសុខសង្គម
    - ជំនួយធានារ៉ាប់រងពេលអត់ការងារធ្វើ
    - កម្មវិធីជំនួយសាធារណៈផ្សេងទៀត។

- DHS|OHA អាចនឹងប្រើលេខ SSN របស់អ្នកដើម្បីរៀបចំបណ្តុំព័ត៌មាន ឬរបាយការណ៍ដែលប្រភពមូលនិធិកម្មវិធីស្នើសុំនៅពេលអ្នកដាក់ពាក្យសុំ ឬទទួលបានជំនួយ។
- DHS និង OHA ប្រហែលជាអាចប្រើ ឬផ្តល់លេខ SSN របស់អ្នកទៅអោយក្រសួងផ្សេង៖
    - ប្រសិនបើយើងត្រូវការផ្ទៀងផ្ទាត់វាដើម្បីដំណើរការលើកម្មវិធីដែលអ្នកដាក់ពាក្យសុំ ឬទទួលបានជំនួយ។
    - ដើម្បីអនុវត្តសកម្មភាពវាយតម្លៃគុណភាព និងកែលម្អ។
    - ដើម្បីផ្ទៀងផ្ទាត់ចំនួនទឹកប្រាក់ត្រឹមត្រូវនៃការទូទាត់ និងទទួលបានជំនួយដែលបានបង់លើស។
    - ដើម្បីផ្ទៀងផ្ទាត់ថាគ្មាននរណាម្នាក់មានជំនួយក្នុងគ្រួសារលើសពីមួយទេ។

យើងមិនទាមទារលេខសូស្យាល់សេគួរិទីសម្រាប់ជំនួយសាច់ប្រាក់សំរាប់ជនភៀសខ្លួន និងជំនួយមើលកូនពេលទៅធ្វើការងារ (ERDC) ទេ។

យើងប្រហែលជាអាចមិនត្រូវការលេខសូស្យាល់សម្រាប់ជំនួយ TA-DVS ។ អ្នកមិនចាំបាច់ទទួលបាន ឬផ្តល់លេខសូស្យាល់អោយយើងទេ ប្រសិនបើវាអាចធ្វើឱ្យអ្នក ឬគ្រួសាររបស់អ្នកប្រឈមមុខនឹងអំពើហិង្សាក្នុងគ្រួសារ។

តាមរយៈហត្ថលេខារបស់ខ្ញុំ (ដែលរួមបញ្ចូលហត្ថលេខាជាពាក្យសំដីផ្ទាល់មាត់ ឬជាអេឡិចត្រូនិក) ខ្ញុំយល់ព្រមដូចខាងក្រោម៖

- ខ្ញុំបានផ្តល់ឱ្យ DHS និង OHA នូវព័ត៌មានពិត ត្រឹមត្រូវ និងពេញលេញ។
- ខ្ញុំចុះហត្ថលេខាលើពាក្យសុំនេះក្រោមការទទួលខុសត្រូវពីច្បាប់។ នោះមានន័យថា ខ្ញុំបានផ្តល់ចម្លើយពិតចំពោះសំណួរទាំងអស់នៅលើបែបបទនេះ។ ខ្ញុំដឹងថា នៅក្រោមច្បាប់សហព័ន្ធ ប្រសិនបើខ្ញុំផ្តល់នូវព័ត៌មានមិនពិត ឬក្លែងបន្លំពត៌មាន នោះខ្ញុំប្រហែលជាអាចនឹងទទួលរងនូវផលដូចខាងក្រោម៖
    - ការផាកពិន័យ
    - ទទួលខុសត្រូវចំពោះការបង់ប្រាក់អោយលើស
- DHS និង OHA អាចពិនិត្យមើលសំណុំរឿងរបស់ខ្ញុំ។ នេះអាចរួមបញ្ចូល DHS មកផ្ទះរបស់ខ្ញុំ។
- ខ្ញុំនឹងរាយការណ៍អំពីការផ្លាស់ប្តូរព័ត៌មានដែលខ្ញុំផ្តល់ឱ្យ DHS និង OHA នៅពេលដែលពួកគេតម្រូវឱ្យខ្ញុំធ្វើ។
- ខ្ញុំបានផ្តល់ព័ត៌មានអំពីសញ្ជាតិពិតប្រាកដអំពីខ្ញុំ និងអ្នកដទៃដែលខ្ញុំស្នើសុំ ឬទទួលបានជំនួយ។
- ខ្ញុំដឹងថា DHS និង OHA នឹងពិនិត្យមើលស្ថានភាពអន្តោប្រវេសន៍របស់ខ្ញុំ និងអ្នកដទៃដែលខ្ញុំស្នើសុំ ឬទទួលបានជំនួយ។
- ខ្ញុំដឹងថាព័ត៌មានដែល DHS និង OHA ទទួលបានពីក្រសួងសញ្ជាតិរូបនីយកម្ម និងអន្តោប្រវេសន៍សហរដ្ឋអាមេរិក

(USCIS) អាចប៉ះពាល់ដល់អ្នកដែលទទួលបានជំនួយ។ DHS និង OHA នឹងមិនទាក់ទងទៅក្រសួង USCIS សម្រាប់អ្នកដែលមិនសុំជំនួយនោះទេ។

- ខ្ញុំអនុញ្ញាតឱ្យចេញផ្សាយនូវកំណត់ត្រាថ្លៃចិញ្ចឹមកូនរបស់ខ្ញុំទៅ DHS និង OHA ពីករសួងយុត្តិធម៌ (DOJ) នាយកដ្ឋានមើលការខុសត្រូវលើថ្លៃចិញ្ចឹមកូន (DCS) ។
- មនុស្សពេញវ័យដែលមានអាយុចន្លោះពី 16 ទៅ 60 ឆ្នាំនៅដែលមានឈ្មោះនៅលើបែបបទនេះ ដែលស្នើសុំជំនួយម្ហូបអាហារ (SNAP) នឹងចុះឈ្មោះសម្រាប់កម្មវិធីរកការងារធ្វើរបស់រដ្ឋ។ ប្រសិនបើខ្ញុំបន្ថែមមនុស្សដែលមានអាយុទាំងនោះទៅក្នុងកម្មវិធីនាពេលអនាគត ពួកគេក៏នឹងត្រូវចុះឈ្មោះចូលផងដែរ។
- ប្រសិនបើខ្ញុំមិនផ្តល់លេខសូស្យាល់សេគ្យូរីទីទៅអោយ DHS និង OHA សម្រាប់អ្នកដែលចង់បានជំនួយទេ នោះពួកគាត់ប្រហែលជាមិនអាចទទួលជំនួយបានទេ។
- DHS និង OHA នឹងមិនប្រើប្រាស់ទូរលេខខាងក្រោម ដើម្បីគណនាជំនួយរបស់ខ្ញុំ ប្រសិនបើខ្ញុំមិនរាយការណ៍ជូនក្រសួងទេ៖
    - ទីជម្រក
    - ជំនួយផ្នែកពេទ្យ
    - ជំនួយចេញថ្លៃមើលកូន
    - ដីកាពីតុលាការស្តីពីការចេញថ្លៃចិញ្ចឹមកូន
- DHS និង OHA ប្រហែលជាអាចប្រើកុំព្យូទ័រដើម្បីពិនិត្យព័ត៌មានទាំងអស់នៅលើបែបបទនេះ។ នេះរួមបញ្ចូលទាំងកំណត់ត្រាដែលត្រូវគ្នាពី៖
    - ធនាគារ
    - ប្រាក់ចំណូល
    - ជំនួយធានារ៉ាប់រងពេលអត់ការងារធ្វើ
- ខ្ញុំយល់ថា DHS និង OHA អាចប្រើ ឬបញ្ចេញលេខ SSN របស់ខ្ញុំ និងលេខ SSN របស់មនុស្សម្នាក់ៗដែលខ្ញុំស្នើសុំបាន។ មូលហេតុសំរាប់ផ្នែកនៃកម្មវិធីទាំងអស់។
- DHS និង OHA អាចផ្តល់ព័ត៌មានអំពីកម្មវិធីនេះទៅ៖
    - ភ្នាក់ងារសហព័ន្ធ និងរដ្ឋដែលធ្វើការពិនិត្យ។
    - មន្ត្រីអនុវត្តច្បាប់ ដើម្បីជួយចាប់ខ្លួនជនណាដែលរត់គេចពីសំណាញ់ច្បាប់។

- ○ ភ្នាក់ងារសហព័ន្ធ និងរដ្ឋ និងភ្នាក់ងារទារបំណុលឯកជន ប្រសិនបើខ្ញុំត្រូវសងជំនួយទៅ DHS ឬ OHA វិញ។
- DHS និង OHA ប្រហែលជាអាចប្រើប្រាស់ព័ត៌មានរបស់ខ្ញុំដើម្បីផ្នែករដ្ឋបាលនៃកម្មវិធីជំនួយសាធារណៈផ្សេងទៀតដែលខ្ញុំទទួលបានពី DHS ឬ OHA ។
- ខ្ញុំយល់ថា DHS ឬ OHA អាចពិនិត្យមើលកន្លែងដែលខ្ញុំប្រើ ឬដកប្រាក់ជំនួយតាមរយៈកាត Oregon Trail របស់ខ្ញុំ។ ខ្ញុំយល់ថាខ្ញុំប្រហែលជាមិនប្រើកាត Oregon Trail របស់ខ្ញុំដើម្បីចាយប្រាក់ជំនួយ ឬដកជំនួយជាសាច់ប្រាក់នៅកន្លែងណាមួយដូចខាងក្រោមឡើយ៖
  - ○ ហាងលក់ស្រា នេះរួមបញ្ចូលទាំងហាងលក់រាយដែលលក់តែសុរា ឬភាគច្រើនលក់ស្រាបៀរ ឬស្រា។
  - ○ កាស៊ីណូ ឬកន្លែងលេងហ្គេម។
  - ○ កន្លែងកម្សាន្តសម្រាប់មនុស្សពេញវ័យដែលប្រកបអាជីវកម្មស្រាតអាសអាភាស។ នេះរួមបញ្ចូលទាំងហាងលក់វីដេអូអាសអាភាស ដែលភាគច្រើនលក់ ឬដាក់តាំងនូវវីដេអូ ឬភាពយន្តអាសអាភាស។
  - ○ កន្លែងលក់កញ្ឆា។

ខ្ញុំយល់ថាបុគ្គលដែលចុះហត្ថលេខាលើពាក្យសុំត្រូវតែសងជំនួយដល់ DHS ឬ OHA នៅពេលដែលមានការបង់ប្រាក់លើសនៅក្នុងសំណុំរឿងរបស់ខ្ញុំ។ អ្នកដែលត្រូវដាក់ពាក្យជាមួយខ្ញុំ និងជនតំណាងដែលមានការអនុញ្ញាតក៏អាចទទួលខុសត្រូវចំពោះការបង់ប្រាក់លើសផងដែរ។

ប្រសិនបើខ្ញុំតែងតាំងជនតំណាងដែលមានការអនុញ្ញាត ឬអ្នកទទួលប្រាក់ជំនួស ខ្ញុំយល់ដូចខាងក្រោមនេះ៖

- ប្រសិនបើពួកគេផ្តល់ព័ត៌មានខុស ឬមិនពេញលេញ ដូច្នេះគ្រួសាររបស់ខ្ញុំទទួលបានជំនួយច្រើនពេក ខ្ញុំនឹងត្រូវសងវិញនូវជំនួយដែលអោយលើសនោះ។
- អ្នកទទួលប្រាក់ជំនួសរបស់ខ្ញុំមានសិទ្ធិពេញលេញដើម្បីប្រើប្រាស់ជំនួយរបស់ខ្ញុំ។ ខ្ញុំមិនអាចទទួលបានសំណងនៃជំនួយទេ ទោះបីជាបុគ្គលនេះចាយជំនួយនោះដោយគ្មានការអនុញ្ញាតពីខ្ញុំ។
- ខ្ញុំមិនអាចប្រើជនតំណាងដែលមានការអនុញ្ញាត ឬអ្នកទទួលប្រាក់ជំនួសនៅក្នុងកម្មវិធី TA-DVS បានទេ។

**ប្រសិនបើខ្ញុំដាក់ពាក្យសុំជំនួយសាច់ប្រាក់** — ខ្ញុំផ្តល់ឱ្យរដ្ឋនូវសិទ្ធិក្នុងការរក្សានូវប្រាក់ជំនួយ។

នេះត្រូវបានគេពន្យល់នៅក្នុងព័ត៌មានក្នុងកម្មវិធី ផ្នែកជំនួយសាច់ប្រាក់។

ខ្ញុំយល់ថាខ្ញុំមិនចាំបាច់សហការណ៍ជាមួយកម្មវិធីចេញថ្លៃចិញ្ចឹមកូនទេ ប្រសិនបើវាមានគ្រោះថ្នាក់សម្រាប់ខ្ញុំ ឬកូនរបស់ខ្ញុំ។

**ប្រសិនបើខ្ញុំដាក់ពាក្យសុំជំនួយសាច់ប្រាក់ និងម្ហូបអាហារ** —

ខ្ញុំយល់ថាខ្ញុំមិនអាចទទួលបានជំនួយអាហារពីកម្មវិធីចែកចាយអាហារសំរាប់តំបន់ជនជាតិអីនឌៀន (FDPIR) និង ជំនួយ SNAP ក្នុងពេលតែមួយបានទេ។

**ប្រសិនបើខ្ញុំដាក់ពាក្យសុំជំនួយមើលកូនទាក់ទងនឹងការងារ** — ខ្ញុំយល់ថាជំនួយមើលកូនណាមួយ

ដែលខ្ញុំទទួលបាននឹងត្រូវបានរាយការណ៍ទៅក្រសួងពន្ធដារនៃរដ្ឋអូរិហ្គិន។ នេះប្រហែលជាអាចប៉ះពាល់ដល់បំណុលពន្ធរបស់ខ្ញុំ ឬលុយដែលអាចបានមកពីការធ្វើពន្ធរបស់ខ្ញុំ។

**ប្រសិនបើខ្ញុំដាក់ពាក្យសុំជំនួយផ្នែកពេទ្យ** - ខ្ញុំយល់ថាសេវាកម្ម និងឧបករណ៍សំភារៈពេទ្យមួយចំនួនទាមទារនូវការអនុញ្ញាតជាមុន (PA)។ ខ្ញុំត្រូវមាន PA ពី DHS ឬ OHA ឬពីគម្រោងសុខភាពដែលមានការចាត់ចែងរបស់ខ្ញុំ មុនពេលខ្ញុំអាចទៅដឹកវាមកផ្ទះបាន។

ខ្ញុំ និងប្តីឬប្រពន្ធរបស់ខ្ញុំយល់ព្រមថា សម្រាប់ប្រាក់ប្រចាំឆ្នាំដែលយើងរាយការណ៍ទៅ DHS ឬ OHA នឹងក្លាយជាអ្នកទទួលផល។